ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៤២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតសាកលវិទ្យាល័យជាតិគ្រប់គ្រង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាស ឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានា នូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពី លក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

# សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១..**

សាកលវិទ្យាល័យជាតិគ្រប់គ្រង អក្សរកាត់ "**ស.ជ.គ**" ត្រូវបានសំរេចឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និង ក្រោមអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២..**

**ស.ជ.គ** ជានីតិបុគ្គល និង មានស្វ័យភាពហិរញ្ញវត្ថុ ។ **ស.ជ.គ** មានអាស័យដ្ឋាននៅ ផ្លូវលេខ៩៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ៣..**

**ស.ជ.គ.** មានភារកិច្ចជាអាទិ៍ ដូចតទៅ ÷

- បណ្តុះបណ្តាលអ្នកជំនាញឯកទេស រយៈពេលខ្លី និង ឧត្តមសិក្សាគ្រប់កំរិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ ធ្វើវិក្រឹតការអ្នកបច្ចេកទេស បង្កើនទាំងបរិមាណ និងគុណភាព ស្របតាមសំណូមពរនៃសេចក្តីត្រូវការទូទាំងព្រះរាជាណាចក្រកម្ពុជា និង រៀបចំបើកសិក្ខាសាលា សន្និសីទផ្សេង ៗ តាមសំណូមពរចាំបាច់របស់សង្គម ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សំរាប់ **ស.ជ.គ** ។
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតំរូវការទីផ្សារការងារ និង ស្តង់ដាអន្តរជាតិ ។
- សិក្សាស្រាវជ្រាវខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន និង ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាជាតិ និង ភាសាបរទេស ឱ្យបានសមស្របសំរាប់ប្រើប្រាស់ ។
- រៀបចំ និង ដំណើរការ ជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រលងចេញ និងស្វ័យវាយតំលៃការសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ និង ប្រកបដោយតម្លាភាព ។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រក្នុងឯកទេសរបស់សាកលវិទ្យាល័យ ។
- កសាងផែនការអភិវឌ្ឍន៍សំរាប់ **ស.ជ.គ** ។
- គ្រប់គ្រងមន្ត្រីរាជការ និយោជិត កម្មករ និស្សិត សាស្ត្រាចារ្យ និង ទ្រព្យសម្បត្តិរបស់ **ស.ជ.គ** ។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និង ស្ថាប័ននានា ក្នុងគោលបំណង ធ្វើឱ្យកាន់តែល្អប្រសើរនូវការសិក្សា ការបង្រៀន និង ការស្រាវជ្រាវ ។

## ជំពូក ២

## រដ្ឋបាល និង ការគ្រប់គ្រង

## ផ្នែកទី ១

## ក្រុមប្រឹក្សាភិបាល

**មាត្រា ៤..**

**ស.ជ.គ** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារ ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ និង បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវមានការយល់ព្រមពីក្រសួងអាណាព្យាបាលទាំងពីរ ។

**មាត្រា ៥..**

៥.១.. ក្រុមប្រឹក្សាភិបាលមានសមាជិក ០៥ រូប ដែលមានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១- តំណាងក្រសួងអប់រំយុវជន និង កីឡា | ១ រូប សមាជិក |
| ២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប សមាជិក |
| ៣- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប សមាជិក |
| ៤- សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង | ១ រូប ជាសមាជិកស្វ័យប្រវត្តិ |
| ៥- តំណាងបុគ្គលិកនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង | ១រូប ជាសមាជិកស្វ័យប្រវត្តិ |

៥.២.. តំណាងបុគ្គលិកសាកលវិទ្យាល័យជាតិគ្រប់គ្រង ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **ស.ជ.គ** ។

៥.៣.. ប្រធាន និង សមាជិកក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើ នៃក្រសួង ឬ ស្ថាប័នដែលខ្លួនតំណាងឱ្យ។

**មាត្រា ៦..**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ៥ ( ប្រាំ ) ឆ្នាំ មានអាយុមិនលើសពី ៦៥ ឆ្នាំ មានបទពិសោធន៍គ្រប់គ្រាន់ និង មានចំណេះដឹងខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច អប់រំឧត្តមសិក្សា ឬនីតិសាស្ត្រដែលមានសញ្ញាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មក្រិតធ្ងន់ពីតុលាការឡើយ។

**មាត្រា ៧..**

**៧.១..** ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និង កំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុម - ប្រឹក្សាភិបាល ។

**៧.២..** ក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើផ្នែកឧត្តមសិក្សា ឬ តំណាងអ្នកផ្តល់ជំនួយចូលរួមក្នុងអង្គប្រជុំ របស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់យោបល់ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

**មាត្រា ៨..**

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំតំរង់ទិសដៅ និង ធ្វើការត្រួតពិនិត្យលើដំណើរការរបស់សាកល-វិទ្យាល័យ ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាល ត្រូវ ÷

- ពិនិត្យ និង សម្រេចលើផែនការអភិវឌ្ឍន៍នៃ **ស.ជ.គ** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និង សម្រេចលើចំណូល និង ចំណាយជាប្រចាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ស.ជ.គ**
- ពិនិត្យ និង សម្រេចលើ របាយការណ៍គ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និង ភារកិច្ចទូទៅ ដល់អង្គភាពក្រោមឱវាទ
- កំណត់បែបបទ នៃការជ្រើសរើស ការតំលើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ស.ជ.គ** ដោយ មិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃច្បាប់ ឬ បទបញ្ជាផ្ទៃក្នុង ដែលអនុវត្តចំពោះភ្នាក់ងារមុខងារ-សាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសំរាប់ **ស.ជ.គ**
- សម្រេចលើកិច្ចសន្យា ស្តីពីលទ្ធកម្ម
- កំណត់បទបញ្ជាផ្ទៃក្នុងនៃ **ស.ជ.គ**
- ធ្វើការវាយតំលៃ តាមចន្លោះពេលទៀងទាត់ លើកំរិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ស.ជ.គ** ហើយកំណត់វិធានការកែតំរូវដើម្បីអនុវត្ត ។

**មាត្រា ៩..**

**៩.១..** លាភការរបស់សមាជិកនៃក្រុមប្រឹក្សាភិបាល និង ប្រាក់បំណាច់របស់សាកលវិទ្យាធិការត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា តាមសំណើរបស់ក្រុមប្រឹក្សា-ភិបាល ។

**៩.២..** លាភការ ឬប្រាក់បំណាច់ខាងលើ អាចត្រូវបញ្ឈប់ចំពោះសមាជិកណាម្នាក់ នៃក្រុមប្រឹក្សាភិបាលដែលមិនមកបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១០.-**

**១០.១.-** ក្រុមប្រឹក្សាភិបាល នៃ **ស.ខ.គ** ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ ប្រធាន ឬតាមការស្នើរបស់សមាជិកចំនួន២/៣(ពីរភាគបី) ឡើងទៅ ឬតាមការស្នើសុំពីសាកលវិទ្យាធិការ នៃ **ស.ខ.គ** ។ ក្នុងករណី ប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ ដែលមានវ័យច្រើនជាងគេក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ តែមិនអាចជ្រើសរើសសមាជិកស្វ័យប្រវត្តិទេ ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ១ (មួយ) រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ។ លេខាធិការនេះ គ្មានសិទ្ធិបោះឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈ និងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និង គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ ។

**១០.២.-** ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមានចំនួនលើសពី ៥០ (ហាសិប) ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមាន គ្មានសិទ្ធិបញ្ជូនតំណាង ឱ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ បើសិនសំឡេងកូរ៉ុមមិនគ្រប់ចំនួន ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំ ម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំ លើកទីមួយ ។ សមាជិកវត្តមាន ត្រូវចុះហត្ថលេខា លើបញ្ជីវត្តមានមួយ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសម្លេងភាគច្រើន នៃសមាជិកវត្តមាន ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព ។

**១០.៣.-** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ និងដំកល់ទុកនៅទីស្នាក់ការរបស់ **ស.ខ.គ** និងត្រូវចុះហត្ថលេខា ដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះ ត្រូវបង្ហាញអត្ថន័យ នៃការពិភាក្សាឱ្យបានច្បាស់លាស់ និង ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និង ផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០(ដប់) ថ្ងៃ ក្រោយពេលប្រជុំ ។

**១០.៤.-** **ស.ខ.គ** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ :

- កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍របស់សាកលវិទ្យាល័យ
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍គ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**១០.៥.-** ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃឡើយ ។

## ជំពូកទី ២
## អង្គការប្រតិបត្តិរបស់សាកលវិទ្យាល័យ

**មាត្រា ១១..**

**ស.ជ.គ** ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ សាកលវិទ្យាធិការនេះ មានតួនាទី ជានាយកប្រតិបត្តិ ។

**មាត្រា ១២..**

១២.១.. សាកលវិទ្យាធិការនៃ **ស.ជ.គ** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និង អនុវត្តការងារ ដែលមានចែងក្នុងច្បាប់ និង អនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

សាកលវិទ្យាធិការមានភារកិច្ច ÷

- រៀបចំការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍ **ស.ជ.គ** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល និង ដាក់ឱ្យដំណើរការ នូវគោលនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សានេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ស.ជ.គ** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យសម្រេច
- ធ្វើរបាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និង រាល់សកម្មភាពផ្សេងទៀត ហើយដាក់ឯកសារទាំងនេះ ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ស.ជ.គ** ក្នុងក៏រិតក្របខ័ណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទី តាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់ **ស.ជ.គ**
- សម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមតាម សេចក្តីសម្រេច របស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិ ដទៃទៀត ស្តីពីបញ្ហានេះ
- ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និង គ្រប់គ្រងការងារទាំងឡាយ ដែលត្រូវបានប្រគល់ឱ្យតាមបទបញ្ជាផ្ទៃក្នុងរបស់ **ស.ជ.គ** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២.. សាកលវិទ្យាធិការ នៃ **ស.ជ.គ** ជាតំណាងរបស់សាកលវិទ្យាល័យក្នុងទំនាក់ទំនងជាមួយតតិយជន។

១២.៣.. សាកលវិទ្យាល័យជាតិគ្រប់គ្រង មានរចនាសម្ព័ន្ធ ដូចតទៅ :

**ក- មហាវិទ្យាល័យ ខ- សាលាក្រោយឧត្តម គ- សាខា ខេត្ត-ក្រុង**

**ឃ-ផ្នែកសិក្សា ស្រាវជ្រាវ និង ផ្សព្វផ្សាយ ង- ផ្នែកគ្រប់គ្រងរដ្ឋបាល និង ហិរញ្ញកិច្ច**

១២.៤..ព្រឹទ្ធបុរសមហាវិទ្យាល័យ នាយកសាលាក្រោយឧត្តម នាយកគ្រប់គ្រងសាខា នាយផ្នែក មានឋានៈស្មើ ប្រធាននាយកដ្ឋាន តែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា និង តាមយោបល់ របស់ ក្រុមប្រឹក្សាភិបាល ។

១២.៥..មហាវិទ្យាល័យ សាលាក្រោយឧត្តម សាខា ខេត្ត-ក្រុង និងផ្នែក មានព្រឹទ្ធបុរសរង នាយករងនិង នាយផ្នែករង មួយចំនួនជាជំនួយការ ដែលតែងតាំងដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ។

## ផ្នែកទី ៣

## បុគ្គលិករបស់ " ស.ជ.គ "

**<u>មាត្រា ១៣</u> :**

១៣ .១ -បុគ្គលិកអចិន្ត្រៃយ៍របស់ **ស.ជ.គ** រួមមានមន្ត្រីរាជការក្របខ័ណ្ឌ មុខងារសាធារណៈ មកពីក្រសួងអប់រំយុវជន និង កីឡា ឬ ជ្រើសរើសតាមសំណើរបស់សាកលវិទ្យាធិការ នៃ **ស.ជ.គ** ។ មន្ត្រីទាំងនេះត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារ សាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

១៣ . ២- សាកលវិទ្យាល័យ អាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យា ជំនួយការ និង បុគ្គលិកអណ្តែត ។ ភ្នាក់ងារទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ ស្តីពីការងារ ។

១៣ . ៣ -បុគ្គលិក **ស.ជ.គ** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជា ស្តីពីបុគ្គលិកសម្រេចដោយក្រុមប្រឹក្សាភិបាល ។ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កំរៃលើកទឹកចិត្ត ចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

## ផ្នែកទី ៤

## ទ្រព្យសម្បត្តិរបស់ " ស.ជ.គ "

**<u>មាត្រា១៤</u> :**

១៤.១ ~ **ស.ជ.គ** ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ :

-ដីជាទីតាំងសាកលវិទ្យាល័យជាតិ គ្រប់គ្រង ស្ថិតនៅផ្លូវលេខ៨៦ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញរាជធានីភ្នំពេញ មានផ្ទៃដី ៧.៨០៣ ម$^2$ ។

១៤ . ២ - ក្រៅពីអចលនទ្រព្យខាងលើ **ស.ជ.គ** ត្រូវបានទទួលនូវចលនទ្រព្យនិងអចលនទ្រព្យផ្សេងៗ ដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣.. អចលនទ្រព្យ និង ចលនទ្រព្យ របស់ **ស.ខ.គ** មានចែងលំអិតក្នុងបញ្ជីសារពើភណ្ឌ ។

១៤.៤.. **ស.ខ.គ** អាចទិញ លក់ចលនទ្រព្យ និង ទិញអចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់ខ្លួន។

## ផ្នែកទី ៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និង គណនេយ្យរបស់ " ស.ខ.គ "

**មាត្រា ១៥..**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ នៃ **ស.ខ.គ**ត្រូវប្រព្រឹត្តស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ៨២អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ឬកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៦..**

១៦.១.. សាកលវិទ្យាធិការ នៃ **ស.ខ.គ** ជាអាណាប័កដើមខ្សែរបស់សាកលវិទ្យាល័យ ហើយត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និង ទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៦.២.. អាណាប័កដើមខ្សែ អាចផ្ទេរសិទ្ធិ ឱ្យអាណាប័កផ្ទេរសិទ្ធិ ឬ អាចបង្កើតរជ្ជទេយ្យចំណូល ឬបុរេប្រទានបានដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

**មាត្រា ១៧..**

១៧.១.. ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ញាផ្ទៃក្នុង របស់ **ស.ខ.គ** ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវសច្ចាប្រណិធានមុនចូលកាន់ការងារ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវទទួលខុសត្រូវចំពោះមុខសាកលវិទ្យាធិការ នៃ **ស.ខ.គ** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែពុំមានសិទ្ធិបោះឆ្នោតឡើយ ។

១៧.២.. ភ្នាក់ងារគណនេយ្យមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ

- រក្សាទុក និង ចាត់ចែងប្រើប្រាស់មូលនិធិ និង ធនធានរបស់សាកលវិទ្យាល័យ
- រក្សាទុកលិខិតយុត្តិការ និង កាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣.. ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុករបស់ខ្លួន ។

**មាត្រា ១៨..**

១៨.១.. ប្រភពធនធានរបស់ **ស.ខ.គ** រួមមាន ÷

- ធនធានដំបូងដែលរដ្ឋផ្តល់ដល់ **ស.ខ.គ** នៅពេលបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និង ឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និង អច្ច័យទាន ដែល **ស.ខ.គ** បានទទួល
- ប្រាក់ខ្ចីបុល ដោយសាកលវិទ្យាល័យផ្ទាល់ និង ប្រាក់ ដែលរដ្ឋខ្ចីបុលឱ្យ **ស.ខ.គ**
- ផលការងារ និង កំរៃនៃការផ្តល់សេវាផ្សេងៗ ដោយ **ស.ខ.គ**
- កំរៃនៃទ្រព្យសម្បត្តិរបស់ **ស.ខ.គ** និង ចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាត ពីរាជរដ្ឋាភិបាល
- កំរៃនៃទ្រព្យសម្បត្តិ ដែលបានប្រគល់ឱ្យ **ស.ខ.គ** ។

១៨.២.. ចំណូលចំណាយ ជាប្រចាំព្រមទាំងមូលធន របស់ **ស.ខ.គ** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ។ ក្រុមប្រឹក្សាភិបាលរបស់ **ស.ខ.គ** ត្រូវចែងអំពីបែបបទ នៃការរៀបចំការចាត់ចែង និង អនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ដែលទាក់ទងដល់ទំរង់បែបបទ នៃការរៀបចំការចាត់ចែង និង អនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣.. អាណាប័កដើមខ្សែនៃ **ស.ខ.គ** ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ដោយមានបញ្ចូលទាំងគំរោងថវិកាលំអិតសំរាប់ឆ្នាំនីមួយៗ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែកញ្ញា នៃឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និង ចំណាយ ។

១៨.៤.. ក្នុងការរៀបចំថវិកាប្រចាំឆ្នាំសំរាប់ **ស.ខ.គ** អាណាប័កដើមខ្សែ ត្រូវរាប់បញ្ចូលថវិកា ដែលឧបត្ថម្ភ ដោយរាជរដ្ឋាភិបាល ។ ថវិកាឧបត្ថម្ភនេះ ត្រូវផ្តល់ឱ្យ **ស.ខ.គ** ដោយអនុលោមតាមមាត្រា ៥១ និង៥២ នៃព្រះរាជក្រឹត្យ លេខនស-រកត-០៣០៣-១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

**មាត្រា ១៩..**

១៩.១.. ការងារគណនេយ្យរបស់ **ស.ខ.គ** រួមមាន ÷

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និង ប្រតិបត្តិការ ដែលអនុវត្តជាមួយតតិយជន

- គណនេយ្យ អសង្ហារឹម រូបធាតុ និង គណនេយ្យតំលៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់ ។

គណនេយ្យរបស់សាកលវិទ្យាល័យត្រូវ ÷

១- ស្របតាមវិធាន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២- គោរពតាមប្លង់គណនេយ្យរបស់ **ស.ប.គ** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ប្លង់គណនេយ្យនេះ ត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

១៩.២.. គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យ និង អាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣(បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២០..**

មូលនិធិរបស់ **ស.ប.គ** គឺជាមូលនិធិសាធារណៈ ដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៦
## របបសារពើពន្ធនៃ " ស.ប.គ "

**មាត្រា ២១..**

លើកលែងតែមានបដិប្បញ្ញត្តិ ដែលចែងដោយច្បាប់ **ស.ប.គ** ត្រូវស្ថិតនៅក្រោមនីតិរូបចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

## ផ្នែកទី ៧
## លទ្ធកម្មរបស់ " ស.ប.គ "

**មាត្រា ២២..**

ការសម្រេច ការអនុវត្ត និង ការត្រួតពិនិត្យ លើលទ្ធកម្មរបស់ **ស.ប.គ** ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិនៃអនុក្រឹត្យ លេខ ៦០ អនក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈនិង បទបញ្ញាដទៃទៀតពាក់ព័ន្ធនឹងបញ្ហានេះ ។

# ជំពូក ៣

# អាណាព្យាបាល

## ផ្នែកទី ១ អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣..**

**២៣.១..** ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ជ.គ** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និង គម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មានពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយសាកលវិទ្យាធិការ ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

**២៣.២..** លិខិតយល់ព្រមត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬ តំណាង ហើយត្រូវ ផ្ញើជូនទៅសាកលវិទ្យាធិការ នៃ **ស.ជ.គ** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ សាកលវិទ្យាធិការ នៃ **ស.ជ.គ** ត្រូវបញ្ជូនពត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណី ដែលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ ឬ គម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍន៍ ឬ គម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍន៍នៃ **ស.ជ.គ** និង ថវិកាចំណាយជាមូលធន មិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬ អាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេល ដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬ អាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៤..**

**២៤.១..** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចមានយោបល់ជំទាស់លើឯកសារដែលត្រូវបានបញ្ជូនមកខ្លួន ដូចមានចែងក្នុងមាត្រា១០ ខាងលើ ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មានរយៈពេល ១ (មួយ) ខែ សម្រាប់លើកឡើងការជំទាស់ទាំងអស់នេះ ។

**២៤.២..** សាកលវិទ្យាធិការនៃ **ស.ជ.គ** ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារ នៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង រិះរកមធ្យោបាយសម្រាប់ ដោះស្រាយការជំទាស់ទាំងនេះ ។ ប្រសិនបើ ក្រុមប្រឹក្សាភិបាល សម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់

ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ស្តីពីបញ្ហានេះ ជាលាយលក្ខណ៍អក្សរ ដល់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២៥..**

២៥.១.. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចលុប ឬ ផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា-ភិបាល ឬ សាកលវិទ្យាធិការ នៃ **ស.ជ.គ** ក្នុងករណីដែលសេចក្តីសម្រេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់សាកលវិទ្យាល័យ
- ផ្ទុយនឹងច្បាប់ និង បទបញ្ជា
- ធ្វើផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

២៥.២.. ការលុបចោល ឬ ការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយមានបញ្ជាក់ពីមូលហេតុ តាមគំនិតផ្ទាល់ខ្លួន ឬ តាមបណ្តឹងពីភាគីនានា ដែលពាក់ព័ន្ធ ។ ការលុបចោល ឬ ការផ្អាកទុកសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់សាកលវិទ្យាធិការ នៃ **ស.ជ.គ** ហើយសាកលវិទ្យាធិការ ត្រូវជូនពត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៦..**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចចាត់ឱ្យធ្វើអធិការកិច្ច ឬ ការត្រួតពិនិត្យការងាររបស់សាកល-វិទ្យាល័យ ក្នុងករណី ដែលយល់ថា ជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និង បែបបទ ដែលមានចែងក្នុងច្បាប់ និង បទប្បញ្ញត្តិ ដែលមានជាធរមាន ។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៧..**

២៧.១.. ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ជ.គ** ត្រូវផ្ញើរបាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មានរយៈពេល ១ (មួយ) ខែ គិតចាប់ថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ មាន ពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដែលបញ្ជូនមកដោយសាកលវិទ្យាធិការ នៃ **ស.ជ.គ** ដើម្បីផ្តល់ ការយល់ព្រមលើឯកសារទាំងនេះ ។

២៧.២.. លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ តំណាងត្រូវផ្ញើទៅសាកលវិទ្យាធិការ នៃ ស.ជ.គ ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ សាកលវិទ្យាធិការ នៃស.ជ.គ ត្រូវជូនពត៌មាននេះដល់ក្រុមប្រឹក្សាភិបាល យ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។ របាយការណ៍គ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ត្រូវបានលើកឡើង ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

**មាត្រា ២៨..**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការ ស.ជ.គ ដូចរៀបរាប់ខាងក្រោម ត្រូវដាក់សុំការអនុញ្ញាតជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមការផ្តល់យោបល់ ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្តីសម្រេចស្តីពីការលក់ ឬ ផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ នៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ២៩..**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូបប្រចាំ ស.ជ.គ ។ មន្ត្រីនេះ មានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និង ជាក្រោយលើ ស.ជ.គ ស្របតាមអនុក្រឹត្យលេខ៨១ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា តាមក្រសួងអង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត-ក្រុង និង តាមអង្គភាពសាធារណៈ ដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា ៣០..**

៣០.១.. ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ នៃ ស.ជ.គ ស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០.២.. ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារគណនេយ្យកណ្តាល នៃរតនាគារជាតិ និង ក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣០.៣.. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬការត្រួត-ពិនិត្យ លើសាកលវិទ្យាល័យ នៅពេលដែលយល់ថាចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៣១..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ០១ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៣២
- -ឯកសារ កាលប្បវត្តិ